## ទិដ្ឋភាពទូទៅនៃកម្មវិធី ៖ គម្រោងមូលនិធិ «ចល័ត» ២០២៤
## កម្មវិធីៈ មូលនិធិ

### ១. តើកម្មវិធីនេះមានប្រតិបត្តិការដូចម្ដេច ?

គម្រោងមូលនិធិ «ចល័ត» គឺជាគម្រោងស្នូលមួយនៅក្នុងកម្មវិធីមូលនិធិនៃអង្គការសិល្បៈខ្មែរអមតៈ។ ជារៀងរាល់ឆ្នាំ យើងតែងតែផ្តល់ឱកាសនេះដល់សិល្បករ និងអ្នកធ្វើការក្នុងវិស័យសិល្បៈវប្បធម៌គ្រប់ទម្រង់ ដើម្បីអភិវឌ្ឍគំនិត និងចំណេះដឹង ផ្លាស់ប្តូរបទពិសោធន៍ កសាងបណ្តាញ និងពង្រឹងសមត្ថភាពក្នុងជំនាញរបស់ខ្លួន តាមរយៈការទៅចូលរួមផ្សេងៗនៅប្រទេសនានាក្នុងតំបន់អាស៊ី។ បេក្ខជនដែលចាប់អារម្មណ៍ចង់ទទួលបានឱកាសគាំទ្រនេះ ត្រូវបំពេញទម្រង់ស្នើសុំដែលយើងបានភ្ជាប់ជាមួយនឹងសេចក្តីប្រកាស ដើម្បីបង្ហាញពីឆន្ទៈ និងអត្ថប្រយោជន៍ដែលខ្លួនរំពឹងទុកពីកម្មវិធី។ បន្ទាប់មក គណៈកម្មការឯករាជ្យនៃគម្រោងមូលនិធិនេះនឹងវាយតម្លៃលើពាក្យស្នើសុំរបស់អ្នក ហើយដាក់ពិន្ទុដើម្បីកំណត់ជ្រើសរើសបេក្ខជនជ័យលាភីសម្រាប់កម្មវិធីនេះ។

### ២. តើគោលដៅរបស់កម្មវិធីមានអ្វីខ្លះ ?

កម្មវិធីនេះមានគោលដៅចង់ជួយគាំទ្រការអភិវឌ្ឍសមត្ថភាពសិល្បករ អ្នកស្រាវជ្រាវ ឬអ្នកស្រាវជ្រាវវប្បធម៌ តាមរយៈការផ្តល់មូលនិធិឱ្យពួកគេទៅចូលរួមក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ មហោស្រព ការធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវ និងកម្មវិធីនិវេសនដ្ឋានសិល្បៈជាដើម។យើងជឿជាក់ថា ការចូលរួមជ្រោមជ្រែងលើការអភិវឌ្ឍសមត្ថភាពធនធានមនុស្សក្នុងវិស័យសិល្បៈ ជាចលករដ៏ចាំបាច់មួយដែលចូលរួមចំណែកក្នុងការពង្រឹងប្រព័ន្ធអេកូសិល្បៈនៅកម្ពុជា។

### ៣. តើអត្ថប្រយោជន៍នៃកម្មវិធីនេះមានអ្វីខ្លះ ?

- បេក្ខជនជ័យលាភីអាចទទួលបានមូលនិធិរហូតដល់១០០០ ដុល្លារ ដើម្បីរ៉ាប់រងលើការធ្វើដំណើរ ការស្នាក់នៅ អាហារ និងតម្លៃចុះឈ្មោះផ្សេងៗ
- មានឱកាសបង្ហាញលទ្ធផលស្រាវជ្រាវ ឬស្នាដៃ តាមរយៈវិធានសិល្បៈរបស់ខ្លួន
- មានឱកាសពង្រីកចំណេះដឹង និងកសាងបណ្តាញជា មួយ នឹង អ្នក ដែល ធ្វើការ ក្នុង វិស័យ ស្រដៀងគ្នានៅក្នុងតំបន់អាស៊ី

### ៤. តើនរណាជាអ្នកចូលរួមគោលដៅសម្រាប់កម្មវិធីនេះ ?

- សិល្បករ និងអ្នកធ្វើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌គ្រប់ទម្រង់ (ដូចជាៈ ភាពយន្ត សិល្បៈទស្សនីយភាព សិល្បៈសូនរូប សហគមន៍អ្នកនិពន្ធ។ល។
- មូលនិធិនេះគឺសម្រាប់តែអ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa ប៉ុណ្ណោះ។

## ៥. តើលក្ខខណ្ឌជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

លក្ខខណ្ឌដែលនឹងប្រើប្រាស់ដើម្បីជ្រើសរើសមូលនិធិនេះ មានដូចជា ៖

1. អ្នកត្រូវបំពេញលើពាក្យស្នើសុំដែលផ្តល់ដោយអង្គការសិល្បៈខ្មែរអមតៈ។ សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងៗ ដែលយើងបានតម្រូវ។ អ្នកអាចបំពេញពាក្យស្នើសុំជាភាសាខ្មែរ ឬអង់គ្លេស ឬថតចម្លើយជាវីដេអូ វីសំឡេងក៏បាន
2. អ្នកអាចបំពេញពាក្យស្នើសុំដោយដៃ ឬដោយកុំព្យូទ័រ។ ប្រសិនបើអ្នកជួបការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០៧៧ ៥៥ ៨៥ ៤៥ ។
3. អ្នកអាចបំពេញពាក្យនេះសម្រាប់ខ្លួនឯង ឬសម្រាប់ក្រុម។ ក្នុងករណីអ្នកបំពេញសម្រាប់ក្រុម សូមបញ្ជាក់តែឈ្មោះតែប្រធានក្រុម ឬអ្នកតំណាងក្រុម។
4. អ្នកត្រូវបង្ហាញពីៈ
   - ការប្តេជ្ញាចិត្តរបស់អ្នកក្នុងការទៅចូលរួមកម្មវិធី
   - ចំណាប់អារម្មណ៍របស់អ្នកអំពីសារៈសំខាន់នៃកម្មវិធី/ដំណើរការសិក្សាស្រាវជ្រាវក្នុងការជួយបន្ថែមគំនិត បទពិសោធន៍ ចំណេះដឹង និងការអភិវឌ្ឍវិស័យសិល្បៈ
   - មានការប្តេជ្ញាចិត្តក្នុងការសរសេររបាយការណ៍សង្ខេបអំពីបទពិសោធន៍ និងចំណេះដឹងដែលអ្នកទទួលបានពីកម្មវិធី
   - ឆន្ទៈក្នុងការៀបចំជំនួបមួយ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីការចូលរួម ជាមួយក្រុម សហគមន៍សិល្បៈ និងក្រុមគោលដៅផ្សេងៗទៀតដែលអ្នកគិតថាទាញប្រយោជន៍ពីការចូលរួមក្នុងជំនួបចែករំលែកនេះ

## គោលការណ៍អាទិភាពៈ

អង្គការសិល្បៈខ្មែរអមតៈលើកទឹកចិត្តដល់សហគមន៍ដែលមានសំឡេងតិច រួមមានៈ សហគមន៍ជនជាតិដើម អ្នកមានពិការភាព ស្ត្រី និងអ្នកដែលមិនធ្លាប់បានទទួលឱកាសទាំងនេះពីមុនមកឱ្យដាក់ពាក្យស្នើសុំ។

*យើងផ្តល់ឱកាស ៥០ ភាគរយ សម្រាប់ស្ត្រី និង២៥ ភាគរយ សម្រាប់អ្នកធ្លាប់ ឬ កំពុងទទួលបានឱកាសទាំងនេះនៅតែអាចដាក់ពាក្យស្នើសុំបានពីការសិល្បៈខ្មែរអមតៈ ។*

## ៦. តើដំណើរការនៃការជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

- នៅពេលអ្នកផ្ញើពាក្យស្នើសុំមកកាន់ពួកយើង ពួកយើងនឹងបញ្ជាក់ប្រាប់ទៅអ្នកវិញ ប្រសិនបើពួកយើងបានទទួល ។ ប្រសិនបើអ្នកមិនបានទទួលដំណឹងពីពួកយើងក្នុងអំឡុងពេល ៣ ថ្ងៃនៃថ្ងៃធ្វើការទេ សូមទាក់ទងមកពួកយើងម្តងទៀត ។

- ពាក្យស្នើសុំទាំងអស់ដែលត្រឹមត្រូវតាមលក្ខខណ្ឌ នឹងត្រូវបានពិនិត្យម្តងទៀតដោយយោងទៅតាមលក្ខខណ្ឌនៃការជ្រើសរើសដែលបានកំណត់ខាងលើ ។
    - ការពិនិត្យមើលនេះ នឹងត្រូវបានធ្វើឡើងដោយគណៈកម្មការជ្រើសរើសឯករាជ្យមួយរូប (ឬលើសពីនេះ)
    - គណកម្មការនឹងប្រើប្រព័ន្ធដាក់ពិន្ទុ ដើម្បីធ្វើឱ្យប្រាកដថាការផ្ទៀងផ្ទាត់ពាក្យស្នើសុំមានភាពត្រឹមត្រូវ និងជាក់លាក់
- បេក្ខជនដែលបានជាប់ដល់ដំណាក់កាលពិនិត្យពាក្យស្នើសុំ នឹងទទួលបានការអញ្ជើញចូលរួមវគ្គសម្ភាស
- បេក្ខជនត្រូវបញ្ជូនសំណើមកកាន់អ្នកសម្របសម្រួលកម្មវិធីយ៉ាងហោចណាស់ ១ ខែ មុនពេលធ្វើដំណើរ ប៉ុន្តែយើងសូមលើកទឹកចិត្តអ្នកឱ្យមុននេះ ប្រសិនបើអ្នកដឹងពីឱកាសនោះជាមុន ។
- ក្នុងករណីដែលអ្នកបញ្ជូនពាក្យស្នើសុំត្រូវក្នុងរយៈពេលតិចជាងមួយខែ អ្នកត្រូវបង្ហាញភស្តុតាងសមរម្យ ឧ. លិខិតពន្យល់ពីអ្នកអញ្ជើញ។ ទោះជាបែបនេះក្តី យើងមិនធានានូវភាពជោគជ័យនៃការស្នើសុំនេះទេ ព្រោះមានតែគណៈកម្មការឯករាជ្យប៉ុណ្ណោះដែលមានសិទ្ធិសម្រេច។

### ៧. តើពេលវេលាអនុវត្តគម្រោងត្រូវស្ថិតក្នុងចន្លោះពេលណា?

អ្នកត្រូវប្រាកដថា គម្រោងរបស់អ្នកត្រូវប្រព្រឹត្តឡើងនៅចន្លោះខែឧសភា ដល់ធ្នូ ឆ្នាំ ២០២៤

### ៨. តើនរណាជាអ្នកសម្របសម្រួលកម្មវិធីនេះ?

ក្រុមការងារអង្គការសិល្បៈអមតៈនឹងសម្របសម្រួលកម្មវិធីនេះ រួមមាន កញ្ញា សាយ តុលា ជាអ្នកសម្របសម្រួលកម្មវិធីមូលនិធិ និង កញ្ញា យ៉ុន សុខខន ជានាយិកាកម្មវិធី។

### ៩. កាលបរិច្ឆេទសំខាន់ៗ

| **កាលបរិច្ឆេទ** | **សកម្មភាព** |
|---|---|
| ការបរិច្ឆេទទួលពាក្យស្នើសុំ | ចាប់ទទួលពាក្យពីខែមេសា ដល់ធ្នូ ឆ្នាំ ២០២៤ |
| ចំនួនបេក្ខជនជ័យលាភី | ២ រូប (នឹងផ្តល់ជូនក្នុងខែផ្សេងគ្នា) |
| សុពលភាពនៃការបញ្ជូនសំណើ | យ៉ាងហោចណាស់ ១ ខែ មុនពេលធ្វើដំណើរ |
| ការឆ្លើយតបលទ្ធផល | រយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលដាក់ពាក្យ |